Asian Communities for Reproductive Justice

# ការពារយុវជនយើង: បោះឆ្នោត ទេ លើសំណើ ៤!

**យុវជនត្រូវការការរក្សាសុខភាព មិនមែនច្បាប់ដែលបង្កើតរបាំងចំពោះការរក្សាសុខភាពទេ**

- យុវជនខ្លះពន្យារពេល ឬចៀសវៀងទៅជួបពិភាក្សាពីរឿងផ្លូវភេទ បើគេគិតថាឪពុកម្តាយនឹងដឹងអំពីរឿងនេះ។ ពេលដែលក្រុមគ្រួសារយើងប្រឈមមុខនឹងការប្រកាន់ពូជសាសន៍ ព្រោះតែយើងជាជនអន្តោប្រវេសន៍ឬដោយពណ៌សំបុរនោះ_ យើងប្រឈមមុខនឹងការលំបាកជាច្រើនចំពោះលទ្ធភាពទទួលការរក្សាសុខភាព។សំណើ ៤ នឹងធ្វើអោយកាន់តែយ៉ាប់យ៉ឺនថែមទៀត។
- សំរាប់យុវជនដែលគ្មានការធានារ៉ាប់រងសុខភាព សេវាឥតគិតថ្លៃនិងរក្សាការសំងាត់ គឺជាប្រភពតែមួយគត់សំរាប់គេក្នុងការថែរក្សាសុខភាពផ្លូវភេទ។ សំណើ ៤ នឹងជារបាំងសំរាប់យុវវ័យក្នុងការទទួលការថែរក្សាសុខភាពគ្រប់ប្រភេទ រួមទាំងសេវាការពារកំណើតសំរាប់យុវជនផងដែរ។

**យុវជនត្រូវការការអប់រំផ្លូវភេទ មិនមែនច្បាប់ដែលដកយកប្រាក់ពីសាលារៀន និងការបំរើផ្សេងៗ**

- យុវជនត្រូវការពត៌មាន និងមធ្យោបាយផ្សេងៗសំរាប់ជាជំនួយក្នុងការថែរក្សាខ្លួនគេឲ្យបានល្អ និងសំរេចចិត្តបានត្រឹមត្រូវ។សំណើ ៤ អាចជាមូលហេតុឲ្យរដ្ឋាភិបាលចំណាយប្រាក់ និងធនធានលើប្រព័ន្ធតុលាការជំនួសឲ្យសាលារៀន។ដូច្នេះហើយបានជាគ្រូបង្រៀន និងទីប្រឹក្សានៅកាលីហ្វ័រញ៉ាប្រឆាំងសំណើ ៤ ។
- យុវជនតែងទទួលការអប់រំផ្លូវភេទពី គិលានុបដ្ឋាយិកាឬវេជ្ជបណ្ឌិត។សំណើ ៤ ធ្វើឲ្យកាន់តែពិបាកចំពោះគេក្នុងការជួបពេទ្យ។ដូច្នេះហើយបានជា គិលានុបដ្ឋាយិកាឬវេជ្ជបណ្ឌិតប្រឆាំងសំណើ ៤ ។
- រដ្ឋាភិបាលទទួលខុសត្រូវឲ្យយុវជនអាចទទួលពត៌មាននិងការរក្សាសុខភាពផ្លូវភេទ។សំណើ ៤ឲ្យរដ្ឋទទួលខុសត្រូវចំពោះទំនាក់ទំនងក្នុងគ្រួសារ។យុវជនត្រូវការ ឲ្យរដ្ឋាភិបាលធ្វើការរបស់ខ្លួន- មិនមែនការងាររបស់យើងទេ។

**យុវវ័យដែលមានផ្ទៃពោះត្រូវការជំនួយ មិនមែនច្បាប់មិនសមហេតុផលដែលបង្កការលំបាកដល់យុវជនដើម្បីទទួលជំនួយពីមនុស្សពេញវ័យ។**

- ភាគច្រើននៃយុវជនប្រាប់ឪពុកម្តាយពីការដែលគេមានផ្ទៃពោះ ដូច្នេះគេទទួលជំនួយ និងអាចសំរេចចិត្តត្រឹមត្រូវ តែទំនាក់ទំនងគ្រួសារល្អមិនអាចជាបញ្ហា។ក្នុងការពិត យុវជនខ្លះត្រូវបដិសេធ បណ្តេញចេញ ឬត្រូវឪពុកម្តាយធ្វើទណ្ឌកម្ម។សំណើ ៤ មិនការពារយុវជនពីទណ្ឌកម្មនេះទេ- គឺ**អាច**នាំទៅដល់ការស៊ើបអង្កេតក្នុងគ្រួសារនាំមកនូវអន្តរាយច្រើនជាងផលល្អ ជាពិសេសគ្រួសារយើងភាគច្រើនជាជនអន្តោប្រវេសន៍គ្មានឯកសារស្របច្បាប់។
- យុវជនត្រូវការជំនួយពីមនុស្សពេញវ័យដែលគេជឿជាក់។គេនឹងសុំជំនួយពីមនុស្សពេញវ័យណាដែលនឹងជួយគេឲ្យមានសុវត្ថិភាព។ សំណើ ៤ ដកយកការសំរេចចិត្តនេះពីយុវជន និងសហគមន៍យើង។
- ឪពុកម្តាយភាគច្រើនមិននិយាយពីរឿងផ្លូវភេទជាមួយកូនៗទេ។សំរាប់ក្រុមគ្រួសារជនអន្តោប្រវេសន៍ ការពិភាក្សារឿងសិចជារឿងមិនសមរម្យ ទោះជាកូនៗជាយុវជនចង់ពិភាក្សាជាមួយឪពុកម្តាយក៏ដោយ។
- ច្បាប់ដែលអោយឪពុកម្តាយដឹង ជាហេតុធ្វើអោយអ្នកមានផ្ទៃពោះពន្យារពេលទៅជួបពិភាក្សាជាមួយពេទ្យ លទ្ធផលបណ្តាលអោយ ជ្រុលពេល មានគ្រោះថ្នាក់ខ្លាំងក្នុងការពន្លូត។យុវជនខ្លះឲ្យអ្នកខុសច្បាប់គ្មានសុវត្ថភាពពន្លូត ឬមានបំណងធ្វើអត្តឃាត ដើម្បីកុំឲ្យឪពុកម្តាយដឹង។
- អ្នកដែលគាំទ្រសំណើ ៤ និយាយថា យុវជនមិនចាំបាច់ឲ្យដំណឹងឪពុកម្តាយ តែអាចវែកញែកចំពោះមុខតុលាការ ប៉ុន្តែនេះជាជំរើសមិនសមហេតុផលសំរាប់បំភ័យ យុវជនដែលមានគភ៌ ជាពិសេសចំពោះអ្នកមិនស្ទូវចេះអង់គ្លេស និងអ្នកដែលគ្មានឯកសារត្រឹមត្រូវស្របច្បាប់តែម្តង។

**នៅថ្ងៃទី ៤ ខែវិច្ឆិកា យើងអាចចូលរួមការពារយុវជនដោយ**
**បោះឆ្នោត ទេ លើសំណើ ៤**

Asian Communities for Reproductive Justice
310 8th St. suite 102, Oakland CA 94607 ✦ ph 510-434-7900 ✦ fax 510-434-7902
www.reproductivejustice.org